# ១៨.ព្រេងទាក់ទងនឹងពិធីសុំទឹកភ្លៀង

---

ទឹកភ្លៀង ជាវត្ថុធាតុមួយដ៏វិសេស ទោះបីរុក្ខជាតិ សត្វក្តី មនុស្សក្តី សឹងអាស្រ័យទឹកភ្លៀងដើម្បីរស់ទាំងអស់ ។ អស់រដូវប្រាំងទាំងមូល ដែលនាយឧទ្យាន ខំស្រោចស្រពដំណាំដោយទឹក តែការចម្រើនលូតលាស់ដំណាំនោះ មិនស្មើនឹងបានទឹកភ្លៀងស្រោចស្រពម្តងទេ ។ ដូច្នេះក្នុងគ្រា ឬឆ្នាំណាដែលខ្វះទឹកភ្លៀង រមែងមានហេតុភ័យបណ្តាលឡើងពីរយ៉ាង គឺ ភ័យអំពីការអត់ឃ្លានម្យ៉ាង ភ័យអំពីរោគាព្យាធិម្យ៉ាង ។ ភ័យអន្តរាយដ៏ធំទាំងពីរយ៉ាងនេះឯងហើយ ជាកត្តាឲ្យទំនៀមសុំភ្លៀង ទៅជាទំនៀមមួយយ៉ាងសំខាន់ ដែលខ្មែរយើងរក្សាទុក បានបិតថេរតមក ។ ការរាំងភ្លៀង តែងធ្វើឲ្យសត្វលោករងទុក្ខវេទនាខ្លាំងបំផុត2 ។

មានសេចក្តីដំណាលថា3 ក្នុងកាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គទ្រង់យោនយកកំណើតជាសត្វត្រីរ៉ស់ ស្ថិតនៅក្នុងស្រះមួយ នាវស្សបុរី ។ កាលនោះ ក្នុងវស្សបុរីទាំងមូល ពុំមានបង្អោរភ្លៀងចុះសោះ, លុះរាំងរ៉ះយូរៗ ទៅ ទឹកបឹង ទឹកត្រពាំង ក៏រីងហួតអស់ ។ ចំណែកស្រះដែលមានស្តេចត្រីរ៉ស់នៅនោះ ក៏រីងខ្លះដែរ នៅសល់តែភក់ខាប់ ។ ពេលនោះ ពួកត្មាត កុក និង ក្រសារទាំងឡាយ នាំគ្នាចុះចឹកត្រីនៅក្នុងស្រះស៊ីយ៉ាងរីករាយ ជារៀងរាល់ថ្ងៃ ។ ស្តេចត្រីរ៉ស់ ក៏បង្គាប់ពួកត្រីទាំងឡាយ ឲ្យមុជចូលជ្រកលាក់ខ្លួនក្នុងភក់យ៉ាងវេទនាណាស់ ។ ថ្ងៃមួយ ស្តេចត្រីរ៉ស់ ជំនុំនឹងត្រីរងគ្រោះឯទៀតថា "តាំងពីពួកយើងមកចាប់កំណើតជាត្រីនេះ មិនដែលធ្វើអ្វីបៀតបៀនសត្វណាម្តងទេ មិនគួរឡើយ យើងមកទទួលការលំបាកយ៉ាងនេះសោះ" ។ គ្រានោះ ស្តេចត្រីរ៉ស់ តាំងអធិដ្ឋានបួងសួងនឹកដល់គុណព្រះរតនត្រ័យថា "សូមតេជះគុណកែវទាំង ៣ ជាទីពឹងរបស់សត្វលោក សូមព្រះអង្គជួយស្រោចស្រង់យើងទាំងឡាយផង !" ។

នៅពេលនោះ ក៏កើតហេតុអស្ចារ្យ គឺក្តៅដល់ទៅអាសនាព្រះអម្រិន្ទាធិរាជ ។ បានជ្រាបហេតុអស្ចារ្យដូច្នេះ ព្រះឥន្ទ្រាធិរាជ ទ្រង់ត្រាស់ប្រើទេវបុត្ត ១ អង្គ ឲ្យបង្អុរភ្លៀងចុះមកសព្វទិសទី លិចទីទាបគ្មានសល់ ។ ស្តេចត្រីរ៉ស់ ព្រមទាំងពពួកត្រីទាំងឡាយ បានសេចក្តីសុខសប្បាយ តាំងពីពេលនោះមក ។

ដោយមានរឿងអស្ចារ្យយ៉ាងនេះឯងហើយ ទើបកាលណាមានការរាំងរ៉ះ អ្នកស្រុក តែងនាំគ្នាធ្វើពិធីសុំទឹកភ្លៀង ដោយមាននិមន្តព្រះសង្ឃសូធ្យធម៌ សុកោន្តោ មានធ្វើស្រះតូចមួយ ហើយរកត្រីរ៉ស់យកទៅដាក់ឲ្យហែលក្នុងទឹកនោះ រួចធ្វើពិធីបួងសួងសុំទឹកភ្លៀងទៅ 4 ។